**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ផ្សារមូលបត្រកម្ពុជា

CSX

**ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា**

ថ្ងៃ ពុធ ១៤ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## សន្និសីទសារព័ត៌មានស្តីពី "ការបង្កើនម៉ោងជួញដូរ"

ថ្ងៃនេះ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) បានរៀបចំសន្និសីទសារព័ត៌មាននៅអគារផ.ម.ក. ក្នុងគោលបំណងផ្សព្វផ្សាយជាសាធារណៈនូវការបង្កើនម៉ោងជួញដូរ និងកាលបរិច្ឆេទដាក់ឱ្យដំណើរការជាផ្លូវការនូវម៉ោងជួញដូរថ្មី។ ការបង្កើនម៉ោងជួញដូរនេះ ត្រូវបានអនុម័តជាផ្លូវការដោយគណៈកម្មការមូលបត្រកម្ពុជា នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ តាមរយៈប្រកាសស្តីពី ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សាររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

ផ.ម.ក. នឹងបង្កើនម៉ោងជួញដូរក្នុងផ្សាររហូតដល់ម៉ោង ៣ រសៀល ពោលគឺបង្កើនពី រយៈពេល ៣ ម៉ោង កន្លះក្នុងមួយថ្ងៃ ទៅ ៧ ម៉ោង ក្នុងមួយថ្ងៃ។ ដូចនេះ រយៈពេលនៃការជួញដូរនឹងកើនឡើងពីរដង បើធៀបនឹងម៉ោងជួញដូរបច្ចុប្បន្ន។ ម៉ោងជួញដូរថ្មីនេះនឹងចាប់ផ្តើមនៅម៉ោង ៨ ព្រឹក និង បិទនៅម៉ោង ៣ រសៀល។ ថ្ងៃជួញដូរ និងវិធីសាស្រ្តជួញដូរក្នុងវគ្គនីមួយៗ នឹងរក្សារនៅដដែល។ ម៉ោងជួញដូរថ្មីនេះ នឹងអនុវត្តជាផ្លូវការចាប់ពីដើមសប្តាហ៍ក្រោយ គឺនៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៩។

| វគ្គ | ម៉ោងបច្ចុប្បន្ន | ម៉ោងថ្មី |
|---|---|---|
| បើក | ៨:០០ ព្រឹក ដល់ ៩:០០ ព្រឹក | ៨:០០ ព្រឹក ដល់ ៩:០០ ព្រឹក |
| និរន្តរ៍ | ៩:០០ ព្រឹក ដល់ ១១:០០ ព្រឹក | ៩:០០ ព្រឹក ដល់ ២:៥០ រសៀល |
| បិទ | ១១:០០ ព្រឹក ដល់ ១១:៣០ ព្រឹក | ២:៥០ រសៀល ដល់ ៣:០០ រសៀល |

ជាមួយម៉ោងជួញដូរថ្មីនេះដែរ ផ.ម.ក.រំពឹងថានឹងទទួលបានលទ្ធផលវិជ្ជមានជាច្រើន តាមរយៈការដាក់ឱ្យដំណើរការម៉ោងជួញដូរវែងជាងមុន។ ផ.ម.ក.នឹងអាចសម្រួលដល់ការជួញដូរឱ្យកាន់តែមានភាពងាយស្រួលជាងមុន ដោយអ្នកចូលរួមទីផ្សារទាំងអស់អាចបទបែនតាមស្ថានភាពទីផ្សារបានរហ័សជាងមុន។ សន្ទនីយភាពទីផ្សារក៏ត្រូវបានរំពឹងទុកថានឹងមានកំណើនខ្ពស់ តាមរយៈការកើនឡើងនៃសកម្មភាពជួញដូរក្នុងទីផ្សារ។ កំណើននេះ នឹងអនុញ្ញាតឱ្យមូលបត្រចុះ

អគារ ផ.ម.ក. វិថីព្រះមហាក្សត្រិយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ: (៨៥៥) ២៣ ៩៥ ៨៨ ៨៨ ទូរសារ: (៨៥៥) ២៣ ៩៥ ៥៥ ៥៨ អ៊ីមែល: info@csx.com.kh គេហទំព័រ: http://www.csx.com.kh

បញ្ជីក្នុងផ្សារទាំងអស់ ជួញដូរក្នុងតម្លៃទីផ្សារពិត (fair price) និង បង្កើនទំនុកចិត្តដល់វិនិយោគិនមកលើទីផ្សារ។ ផ.ម.ក.ជឿជាក់ថា ការកែសម្រួលនេះ នឹងបង្កើនចំណូល និងការងារ ក្នុងវិស័យមូលបត្រនេះផងដែរ។ កំណើននេះ នឹងផ្តល់ជាធនធានដ៏សំខាន់ សំរាប់ ផ.ម.ក.ក៏ដូចជា ស្ថាប័នដទៃទៀត ក្នុងវិស័យនេះ ដើម្បីបន្តខិតខំផ្តល់ជូននូវ ផលិតផល និង សេវាកម្មឱ្យកាន់តែប្រសើរឡើង។

ផ.ម.ក. រំពឹងថា ម៉ោងជួញដូរថ្មីនេះ គឺជាជំហានថ្មីមួយទៀត ដើម្បីក្លាយខ្លួនជាទីផ្សារអន្តរជាតិ។ ម៉ោងជួញដូរថ្មីដែលកើនឡើងដល់ ៧ ម៉ោងក្នុងមួយថ្ងៃ នឹងផ្តល់ភាពងាយស្រួលដល់វិនិយោគិនបរទេស ដែលរស់នៅប្រទេសដែលមានល្វែងម៉ោងខុសពីកម្ពុជា ក្នុងការជួញដូរមូលបត្រនៅ ផ.ម.ក. ។ ជាមួយគ្នានេះដែរ វាក៏ផ្តល់នូវឱកាស ក្នុងការពង្រីកនូវកិច្ចសហប្រតិបត្តិការជាមួយនឹងទីផ្សារមូលបត្រដទៃ ក្នុងការអភិវឌ្ឍនូវផលិតផលឆ្លងដែនផ្សេងៗ និង បង្កើនភាពប្រកួតប្រជែងទីផ្សាររបស់ខ្លួនជាមួយទីផ្សារដទៃក្នុងតំបន់។

ដោយហេតុថាម៉ោងជួញដូរថ្មីនេះ នឹងចាប់ផ្តើមអនុវត្តពីដើមសប្តាហ៍ក្រោយ ផ.ម.ក. សង្ឃឹមថា វិនិយោគិនទាំងអស់នឹងចូលរួមជួញដូរក្នុងទីផ្សារអោយបានច្រើនកុះករ ដើម្បីទាញយកប្រយោជន៍នៃម៉ោងជួញដូរថ្មីនេះ។

**ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោកស្រី **គីម សុផានីតា** ប្រធាននាយកដ្ឋាន
នាយកដ្ឋានប្រតិបត្តិការទីផ្សារ
អ៊ីម៉ែល៖ sophanita.kim@csx.com.kh